ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៤៥៩ ព.ណ.ករ

ថ្ងៃព្រហស្បតិ៍ ៩ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

ក្នុងនាមគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ធុរជន សហគ្រិន វិនិយោគិន និងផលិតករទាំងអស់ឲ្យបានជ្រាបថា៖ លេខាធិការដ្ឋានពិព័រណ៍ចិន-អាស៊ាន រួមសហការជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ នឹងបន្តរៀបចំពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ានលើកទី១៧ ឆ្នាំ២០២០ "The 17th China-ASEAN Expo 2020" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧-៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិ ទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន។

ដោយស្ថានភាពនៃជំងឺកូវីដ-១៩ មិនទាន់គ្រប់គ្រងបានទាំងស្រុង និងភាពមិនច្បាស់លាស់អំពីស្ថានភាពនៃជំងឺនេះនៅឡើយ លេខាធិការដ្ឋានពិព័រណ៍ចិន-អាស៊ាន សូមអញ្ជើញ ក្រុមហ៊ុន សហគ្រាសកម្ពុជា ដែលមានសាខា ឬ ដៃគូ ឬភ្នាក់ងារលក់ របស់ខ្លួននៅក្នុងប្រទេសចិនស្រាប់ ដើម្បីចូលរួមតាំងបង្ហាញផលិតផល និងស្វែងរកដៃគូពាណិជ្ជកម្ម និងវិនិយោគ នៅក្នុងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ខាងលើ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញធុរជន សហគ្រិន វិនិយោគិន និង ផលិតករទាំងអស់ ដែលមានបំណងបន្តនិរន្តភាពពាណិជ្ជកម្ម ជាមួយដៃគូឬភ្នាក់ងាររបស់ខ្លួន ដែលមានទីតាំងនៅក្នុងប្រទេសចិនស្រាប់ ចូលរួមពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ាន លើកទី១៧ ឆ្នាំ២០២០ សូមប្រញាប់រួសរាន់មកបំពេញបែបបទ នៅនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ឲ្យ**បានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ជាកំណត់។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១៧ ៧៥៩ ៥៦៧ ឬ ០៨៦ ៣៣៣ ៩៣៣ ឬ ០១២ ៦០០ ៧៧៨
០១៧ ៥៥៩ ២៧៧ ឬ ០១៧ ៤៩៥ ០៩១

អាសយដ្ឋានអ៊ីម៉ែល៖ vannameass@yahoo.com ឬ sorn_pitou@yahoo.com
veasna_mao@yahoo.com ឬ vithoh@yahoo.com
kdi_mpp@yahoo.com។

សូមអរគុណ!

ក្រសួងពាណិជ្ជកម្ម

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N° 2656 MOC.D/EA.

Phnom Penh, 27 August, 2020

**ANNOUNCEMENT**

On behalf of the Cambodian Inter-Ministerial Committee for Participation in the World Expo and the International Trade Exhibitions, the Ministry of Commerce has the great honor to inform to all businessmen, entrepreneurs, investors and producers that China-ASEAN Expo Secretariat in collaboration with ASEAN member states will be organizing "The 17th China-ASEAN Expo 2020" to be held from 27th -30th November, 2020 at Nanning International Convention and Exhibition Center, Nanning City, Guangxi Zhuang Autonomous Region of People's Republic of China.

Due to the uncertainty of COVID-19 situation, China-ASEAN Expo Secretariat would like to invite the companies only those who have trade and investment partners based in China to showcase their products or investment projects in the above-mentioned event.

In this regard, the Ministry of Commerce is pleased to invite all businessmen, entrepreneurs, investors and producers who have trade and investment partners in China and intend to participate in "The 17th China-ASEAN Expo 2020" or are looking for their trade and investment partners during the event to apply and register at Department of Exhibition Affairs, General Directorate of Trade Promotion of the Ministry of Commerce no later than 30th September 2020.

For further information, please contact the Department of Exhibition Affairs, General Directorate of Trade Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd, Phum Toek Thla, Sangkat Toek Thla, Khan Sen Sok, Phnom Penh, Cambodia.

Tel: 017 759 567 / 086 333 933 / 012 600 778 / 017 559 277/ 017 495 091

E-mail: vannameass@yahoo.com / sorn_pitou@yahoo.com /veasna_mao@yahoo.com
vitholt@yahoo.com / kdi_mpp@yahoo.com

Thank you!